ឯកសារទិន្នន័យគម្រោង (PDS) ដែលបកប្រែនេះ គឺផ្អែកទៅតាមសំណៅភាសាអង់គ្លេសចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ។

ADB

# ឯកសារទិន្នន័យគម្រោង

ឯកសារទិន្នន័យគម្រោង (PDS) រួមមាន ព័ត៌មានសង្ខេបអំពីគម្រោង ឬកម្មវិធី ៖ ដោយសារតែ PDS គឺជាការងារដែលត្រូវធ្វើជាបន្តបន្ទាប់ ព័ត៌មានមួយចំនួនអាចមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងសំណៅដំបូងនេះនៅឡើយ ប៉ុន្តែនឹងត្រូវបន្ថែម នៅពេលដែលមាន ។ ព័ត៌មានអំពីគម្រោងដែលត្រូវបានស្នើឡើង គឺត្រឹមតែជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ ។

| | |
|---|---|
| **កាលបរិច្ឆេទបង្កើត PDS** | – |
| **PDS ត្រូវបានធ្វើបច្ចុប្បន្នកម្មត្រឹម** | ១០ វិច្ឆិកា ២០១៤ |

| | |
|---|---|
| **ឈ្មោះគម្រោង** | គម្រោងកែលំអផ្លូវជនបទ ដំណាក់កាលទី ២ |
| **ប្រទេស** | ប្រទេសកម្ពុជា |
| **លេខគម្រោង/កម្មវិធី** | ៤២៣៣៤-០១៤ |
| **ស្ថានភាព** | បានអនុម័តរួចហើយ |
| **ទីតាំងភូមិសាស្ត្រ** | – |

នៅក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រប្រចាំប្រទេសណាក៏ដោយ ការផ្តល់ហិរញ្ញប្បទានដល់គម្រោងអ្វីក៏ដោយ ឬការលើកឡើងឬយោងលើដែនដី ឬតំបន់ភូមិសាស្ត្រណាមួយនៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី មិនមានបំណងធ្វើការវិនិច្ឆ័យអំពីស្ថានភាពគតិយុត្តិ ឬស្ថានភាពដទៃទៀតរបស់ដែនដី ឬតំបន់នោះឡើយ ។

| | |
|---|---|
| **ចំណាត់ថ្នាក់វិស័យ និង/ឬអនុវិស័យ** | – |
| **ចំណាត់ថ្នាក់ប្រធានបទ** | – |
| **ប្រភេទនៃការបញ្ជ្រាបយេនឌ័រ** | – |

## ■ ការផ្ដល់ហិរញ្ញប្បទាន

| ប្រភេទ/ទម្រង់នៃការផ្ដល់ជំនួយ | លេខអនុម័ត | ប្រភពមូលនិធិ | ចំនួនដែលត្រូវបានអនុម័ត (គិតជាពាន់) |
|---|---|---|---|
| កម្ចី | ៣១៥១ | មូលនិធិអភិវឌ្ឍន៍អាស៊ី | ៥៤.០០០ |
| ជំនួយឥតសំណង | ០៤០២ | ជំនួយអូស្ត្រាលី | ៦.៦៧០ |
| ជំនួយឥតសំណង | ០៤០១ | មូលនិធិអភិវឌ្ឍន៍ Nordic | ៥.៤០០ |
| – | – | សមភាគី | ១១.១៦០ |
| **សរុប** | | | **៧៧.២៣០** ដុល្លារ |

## ■ ប្រភេទនៃការគាំពារផ្នែកបរិស្ថាន និងសង្គម

សម្រាប់ព័ត៌មានបន្ថែមអំពីប្រភេទនៃការគាំពារផ្នែកបរិស្ថាន និងសង្គម សូមមើល
http://www.adb.org/site/safeguards/safeguard-categories

| | |
|---|---|
| **បរិស្ថាន** | B |
| **ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត** | C |
| **ក្រុមជនជាតិដើមភាគតិច** | C |

## ■ សង្ខេបបញ្ហាបរិស្ថាន និងសង្គម

**ទិដ្ឋភាពបរិស្ថាន**

ប្រភេទបរិស្ថាន សម្រាប់គម្រោងនេះគឺ B ដោយសារតែលក្ខណៈនៃគម្រោង ដែលត្រូវបានលើកស្នើនេះ (ពោលគឺការកែលំអផ្លូវដែលមានស្រាប់ ពុំមានការពង្រីកផ្លូវ ជាដើម ។ល។) ។ គម្រោងផ្លូវថ្នល់មួយចំនួន នៅក្នុងខេត្តបាត់ដំបង និងពោធិសាត់ មានទីតាំងនៅក្នុងតំបន់អន្តរកាលនៃជីវមណ្ឌលបម្រុងបឹងទន្លេសាប (TLSBR) ។ លើសពីនេះ សកម្មភាពមួយចំនួន ដែលស្ថិតក្រោមលទ្ធផលនៃគម្រោងកែលំអទំនាក់ទំនងសម្រាប់ដែនកោះក្នុងទន្លេមេគង្គ រួមទាំង ការសាងសង់នូវទំនប់រលកចំនួន ១១ កន្លែង នឹងធ្វើឡើងជិតទន្លេមេគង្គ ។ បើទោះបីជាពុំមានសកម្មភាពណាមួយរបស់គម្រោង ត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើ

តំបន់ជិតនោះក៏ដោយ (ពោលគឺតំបន់អន្តរកាលនៃជីវមណ្ឌលបម្រុងបឹងទន្លេសាប និងទន្លេងមេគង្គ) ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលការមិនបដិសេធសម្រាប់ការអនុវត្តគម្រោងនេះ ពីអាជ្ញាធរពាក់ព័ន្ធ (ដូចជា ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម និងគណៈកម្មការទន្លេមេគង្គកម្ពុជា) ។ ការពិនិត្យបរិស្ថានដំបូង ដូចជា លើលទ្ធផលរបស់គម្រោងភ្ជាប់ទំនាក់ទំនងរវាងដែនកោះក្នុងទន្លេមេគង្គ រួមទាំងក្របខ័ណ្ឌវាយតម្លៃ និងពិនិត្យឡើងវិញលើបរិស្ថានរបស់គម្រោងនេះ ត្រូវបានរៀបចំឡើង ស្របតាមគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

### ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត

ដោយសារតែពុំមានផ្លូវណាមួយក្នុងគម្រោងនេះនឹងត្រូវពង្រីក ផលប៉ះពាល់លើការតាំងទីលំនៅ ត្រូវបានគេរំពឹងថាមានកម្រិតទាប ។ ដូច្នេះ គម្រោងនេះត្រូវបានដាក់ចំណាត់ថ្នាក់ថាជាគម្រោងប្រភេទ C សម្រាប់ការតាំងទីលំនៅ ក្រោមគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ តែទោះជាយ៉ាងណាក៏ដោយ ក្របខ័ណ្ឌតាំងទីលំនៅមួយត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាននេះ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត នៅក្នុងករណីដែលមានផលប៉ះពាល់ទាំងនេះកើតមានឡើង ដោយសារតែការពង្រីកផ្លូវ នៅក្នុងកំឡុងពេលនៃការអនុវត្តគម្រោង ។

### ក្រុមជនជាតិដើមភាគតិច

ដោយសារតែការវាយតម្លៃសង្គម នៅក្នុងតំបន់គម្រោង នៅក្នុងពេលរៀបចំគម្រោង ពុំមានបង្ហាញពីវត្តមានរបស់ជនជាតិដើមភាគតិច គម្រោងនេះត្រូវបានដាក់ចំណាត់ថ្នាក់ថាជាគម្រោងប្រភេទ C សម្រាប់ជនជាតិដើមភាគតិច ក្រោមគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ■ ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធ

### ក្នុងកំឡុងពេលរៀបចំគម្រោង

–

### ក្នុងកំឡុងពេលអនុវត្តគម្រោង

–

## ■ សេចក្តីពិពណ៌នា

គម្រោងនេះ នឹងស្តារឡើងវិញនូវផ្លូវជនបទប្រវែង ១.០០០ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ៩ (កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង កំពង់ស្ពឺ សៀមរាប បន្ទាយមានជ័យ និងតាកែវ) ឱ្យក្លាយជាផ្លូវក្រាលកៅស៊ូ ដើម្បីបង្កើតនូវបណ្តាញផ្លូវជនបទ ដែលផ្តល់សុវត្ថិភាពជាងមុន និងមានប្រសិទ្ធភាពចំណាយ និងផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋទៅដល់ទីផ្សារ និងទទួលបានសេវាសង្គមដទៃទៀតពេញមួយឆ្នាំ។ គម្រោងនេះក៏នឹងផ្តល់ការគាំទ្រដល់របបថែទាំផ្លូវប្រកបដោយនិរន្តរភាព នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ដល់កម្មវិធីសុវត្ថិភាពផ្លូវថ្នល់តាមជនបទ ដល់កម្មវិធីបង្ការទប់ស្កាត់ និងបង្កើនការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ និងការជួញដូរមនុស្ស និងវិធានាការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនានា។

## ■ សនិទានភាព និងទំនាក់ទំនងរបស់គម្រោងជាមួយនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់

–

## ■ ផលប៉ះពាល់នៃការអភិវឌ្ឍ

បង្កើនលទ្ធភាពទទួលបានទីផ្សារ ការងារ និងសេវាសង្គម នៅក្នុងខេត្តចំនួន ៩ របស់គម្រោង។

## ■ លទ្ធផលរយៈពេលមធ្យមរបស់គម្រោង

| សេចក្តីពិពណ៌នាអំពីលទ្ធផលរយៈពេលមធ្យម | វឌ្ឍនភាពឆ្ពោះទៅសម្រេចលទ្ធផលរយៈពេលមធ្យម |
|---|---|
| បណ្តាញផ្លូវជនបទ ដែលមានសុវត្ថិភាព ធន់ទៅនឹងអាកាសធាតុ និងប្រកបដោយប្រសិទ្ធភាព ដែលផ្តល់នូវលទ្ធភាពទទួលបានសេវាពេញមួយឆ្នាំ សម្រាប់តំបន់កសិកម្មនានា ក្នុងខេត្តទាំង ៩ របស់គម្រោង។ | – |

## ■ លទ្ធផល និងវឌ្ឍនភាព

| សេចក្តីពិពណ៌នាអំពីលទ្ធផលរបស់គម្រោង | ស្ថានភាពនៃការអនុវត្ត (លទ្ធផល សកម្មភាព និងបញ្ហា) |
| --- | --- |
| ១. ការកែលំអផ្លូវជនបទ នៅក្នុងខេត្តចំនួនប្រាំបួន ២. ការបង្កើនសុវត្ថិភាពផ្លូវជនបទ និងការបង្កើនការយល់ដឹងរបស់សហគមន៍ ៣. ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព ៤. ការបង្កើនការភ្ជាប់ទំនាក់ទំនងលើដែនកោះក្នុងទន្លេមេគង្គ ៥. ការពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិផ្លូវជនបទ។ | – |

| ស្ថានភាពនៃគោលដៅអភិវឌ្ឍ | ការផ្លាស់ប្តូរសំខាន់ៗ |
| --- | --- |
| – | – |

## ■ ឱកាសធុរកិច្ច

**កាលបរិច្ឆេទនៃការចុះបញ្ជីដំបូង** ១១ វិច្ឆិកា ២០១៣

**សេវាពិគ្រោះយោបល់**

រាល់ទីប្រឹក្សាទាំងអស់ ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវបានជ្រើសរើស ស្របតាមគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការប្រើប្រាស់ទីប្រឹក្សា។ សេវាផ្តល់ប្រឹក្សា ដែលទទួលបានហិរញ្ញប្បទានពីធនាគារអាហ័រណេ-នីហ័រណេកូរ៉េ និងមូលនិធិអភិវឌ្ឍន៍ Nordic នឹងធ្វើតាមនីតិវិធីជ្រើសរើសទីប្រឹក្សារបស់ធនាគារទាំងពីរនេះ។

**លទ្ធកម្ម**

នីតិវិធីដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ នឹងត្រូវប្រើប្រាស់ សម្រាប់កិច្ចសន្យាសាងសង់ ដែលគេរំពឹងថា មានតម្លៃចាប់ពី ១.០០០.០០០ ដុល្លារឡើងទៅ។ នីតិវិធីដេញថ្លៃប្រកួតប្រជែងក្នុងប្រទេស សម្រាប់ទំនិញ នឹងត្រូវប្រើប្រាស់សម្រាប់កិច្ចសន្យាទាំងឡាយណា ដែលមានតម្លៃប៉ាន់ស្មានចន្លោះពី ១០០.០០០ ដល់ ៥០០.០០០ ដុល្លារ។ ការទិញទំនិញ នឹងត្រូវបានប្រើប្រាស់សម្រាប់កិច្ចសន្យាលទ្ធកម្មសំណង់ និងការទិញឧបករណ៍សម្ភារ ដែលមានតម្លៃទាបជាង ១០០.០០០ ដុល្លារ។

**សេចក្តីជូនដំណឹងអំពីលទ្ធកម្ម និងការពិគ្រោះយោបល់ សូមមើល:**

http://www.adb.org/projects/42334-014/business-opportunities

## ■ កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ៤ កុម្ភៈ ២០១៣ |
| បេសកកម្មស្វែងរកការពិត | ៤ កក្កដា ២០១៣ ដល់ ២២ កក្កដា ២០១៣ |
| កិច្ចប្រជុំពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង | ១០ មេសា ២០១៤ |
| ការអនុម័ត | ៨ សីហា ២០១៤ |
| បេសកកម្មពិនិត្យឡើងវិញចុងក្រោយ | – |

## ■ ចំណុចដៅ

| លេខអនុម័ត | ការអនុម័ត | ចុះហត្ថលេខា | ចូលជាធរមាន | បិទ | | |
|---|---|---|---|---|---|---|
| | | | | សំណៅដើម | ត្រូវបានកែសម្រួល | ជាក់ស្តែង |
| កម្ចី ៣១៥១ | ៨ សីហា ២០១៤ | ២៧ តុលា ២០១៤ | – | ៣១ ធ្នូ ២០២០ | – | – |

## ■ ការប្រើប្រាស់

| កាលបរិច្ឆេទ | ការអនុម័តលេខ | ADB (ពាន់ US$) | ផ្សេងៗទៀត (ពាន់ US$) | ភាគរយជាក់ស្តែង |
|---|---|---|---|---|
| ចំនួនសរុបក្នុងការផ្តល់កិច្ចសន្យា | | | | |
| ២៤ វិច្ឆិកា ២០១៤ | កម្ចី ៣១៥១ | 0 | 0 | 0,00% |
| ការបើកប្រាក់សរុប | | | | |
| ២៤ វិច្ឆិកា ២០១៤ | កម្ចី ៣១៥១ | 0 | 0 | 0,00% |

## ■ ស្ថានភាពនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងត្រូវបានបែងចែកតាមប្រភេទដូចតទៅ - របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងដែលត្រូវបានធ្វើសវនកម្មរួចការគាំពារបិស្ថានសង្គមកិច្ចការសង្គម កិច្ចការវិស័យហិរញ្ញវត្ថុ សេដ្ឋកិច្ច និងកិច្ចការផ្សេងៗទៀត។ ការអនុលោមទៅតាមកិច្ចព្រមព្រៀងត្រូវបានដាក់ពិន្ទុទៅតាមប្រភេទដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចតទៅ:(១)ពេញចិត្ត: អនុលោមទាំងអស់ទៅតាមគ្រប់កិច្ចព្រមព្រៀងដោយមានករណីលើកលែងច្រើនបំផុតត្រឹម ១ ដែលអនុញ្ញាតឱ្យ

មាន (២) ពេញចិត្តដោយអន្លឹះច្រើនបំផុតមានកិច្ចព្រមព្រៀងចំនួន ២ ដែលមិនត្រូវបានអនុលោមតាម (៣) មិនពេញចិត្តៈ មានកិច្ចព្រមព្រៀងចាប់ពី ៣ ឡើងទៅដែលមិនត្រូវបានអនុលោមតាម។  យោងតាមគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈឆ្នាំ ២០១១ ការវាយតម្លៃនៃភាពអនុលោមរបស់កិច្ចព្រមព្រៀងសម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងអនុវត្តតែចំពោះគម្រោងដែលលិខិតអញ្ជើញឱ្យចរចាក្រោយថ្ងៃទី ២ ខែ មេសាឆ្នាំ ២០១២ តែប៉ុណ្ណោះ។

| ការអនុម័តលេខ | ប្រភេទ | | | | | | |
|---|---|---|---|---|---|---|---|
| | វិស័យ | សង្គម | ហិរញ្ញវត្ថុ | សេដ្ឋកិច្ច | ផ្សេងៗ | ការគាំពារបរិស្ថាន និង សង្គម | របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង |
| កម្ចី ៣១៥១ | – | – | – | – | – | – | – |
| ជំនួយឥតសំណង ០៤០២ | – | – | – | – | – | – | – |
| ជំនួយឥតសំណង ០៤០១ | – | – | – | – | – | – | – |
| – | – | – | – | – | – | – | – |

## ■ ការទំនាក់ទំនង និង ព័ត៌មានបច្ចុប្បន្នភាព

| | |
|---|---|
| **មន្ត្រី ADB ដែលទទួលខុសត្រូវ** | Shihiru Date (sdate@adb.org) |
| **នាយកដ្ឋាន ADB ដែលទទួលខុសត្រូវ** | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| **ការិយាល័យ ADB ដែលទទួលខុសត្រូវ** | ផ្នែកដឹកជញ្ជូន និងទំនាក់ទំនង នៃ នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| **ទីភ្នាក់ងារប្រតិបត្តិ** | – |

## ■ ឯកសារសម្រាប់មើលព័ត៌មានផ្សេងៗ

| | |
|---|---|
| **គេហទំព័ររបស់គម្រោង** | http://www.adb.org/projects/42334-014/main |
| **បញ្ជីឯកសារគម្រោង** | http://www.adb.org/projects/42334-014/documents |